មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧

## របាយការណ៍បង្ហាញពីផលលំបាកមួយចំនួនរបស់ខ្មែរក្រោមក្នុងការទទួលបានសិទ្ធិជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា

នៅថ្ងៃសុក្រ **ទី២៧ ខែមករា ឆ្នាំ២០១៧** នេះ អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (“ក.ដ.ទ”) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) និង សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (“ស.ខ.ក.ក.ស.ម.អ”) ចេញផ្សាយរបាយការណ៍មួយក្រោមចំណងជើងថា *“សិទ្ធិជាពលរដ្ឋរបស់ខ្មែរក្រោមនៅកម្ពុជា”* (របាយការណ៍)។ របាយការណ៍នេះអាចទាញយកបានជាភាសាខ្មែរ និងអង់គ្លេស។

ទោះបីជារាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានប្រកាសជាសាធារណៈថា សមាជិកនៃក្រុមជនភាគតិចជាខ្មែរកម្ពុជាក្រោម (“ខ្មែរក្រោម”) គឺជាប្រជាពលរដ្ឋខ្មែរក្តី តែក្នុងស្ថានភាពជាក់ស្តែង ច្បាប់ជាតិពុំបានចែងពីបែបបទផ្នែករដ្ឋបាល ឬផ្លូវច្បាប់ឱ្យបានជាក់លាក់ ដើម្បីឱ្យខ្មែរក្រោមអាចទទួលបានសិទ្ធិនេះនៅឡើយទេ។ លក្ខខណ្ឌតម្រូវតឹងរ៉ឹងសម្រាប់បុគ្គលម្នាក់ៗក្នុងការទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលមានចែងក្នុងច្បាប់ស្តីពីសញ្ជាតិ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា មានន័យថា ក្នុងការអនុវត្តជាក់ស្តែង ខ្មែរក្រោមជាច្រើនពុំអាចទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណ និងទទួលបានសិទ្ធិផ្សេងៗដែលបុគ្គលម្នាក់គួរទទួលបានក្នុងនាមជាពលរដ្ឋនោះទេ។ ការស្រាវជ្រាវនេះមានបំណងផ្តល់ទិន្នន័យជាក់លាក់តាមបែបវិទ្យាសាស្ត្រអំពីស្ថានភាពផ្លូវច្បាប់របស់ខ្មែរក្រោមក្នុងប្រទេសកម្ពុជា រួមទាំងទិន្នន័យទាក់ទងទៅនឹងបទពិសោធន៍ និងផលលំបាកនានាដែលខ្មែរក្រោមបានប្រឈមដោយសារតែកង្វះឋានៈជាពលរដ្ឋរបស់ពួកគាត់ ដោយមានយោងទៅលើឧបសគ្គមួយចំនួនក្នុងការស្នើសុំអត្តសញ្ញាណប័ណ្ណ។

របាយការណ៍នេះផ្អែកទៅលើរបកគំហើញនៃការស្រាវជ្រាវ ដែលមានការចូលរួមពីខ្មែរក្រោមចំនួន ២៦៤ នាក់ នៅក្នុងខេត្តចំនួន ៧ និងរាជធានីភ្នំពេញរបស់កម្ពុជា ដែលបានធ្វើឡើងចាប់ពីខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០១៦។ របកគំហើញបានបង្ហាញថា ខ្មែរក្រោមដែលពុំមានអត្តសញ្ញាណប័ណ្ណបន្តប្រឈមនឹងផលលំបាកនានាក្នុងការរស់នៅក្នុងប្រទេសកម្ពុជា រួមមាន ការរើសអើង កង្វះលំនៅដ្ឋាន និងកង្វះការទទួលស្គាល់ពីអាជ្ញាធរមួយចំនួន។ ក្នុងចំណោមអ្នកឆ្លើយតបការស្ទង់មតិ ចំនួន ៦០,៦០% បានលើកឡើងពីការរើសអើង ដែលជាបញ្ហាចម្បងមួយក្នុងចំណោមផលលំបាក ឬបញ្ហាប្រឈមនានាដែលពួកគាត់ជួបប្រទះនៅកម្ពុជា។

បញ្ហាដែលគួរឱ្យបារម្ភនោះ របាយការណ៍នេះបង្ហាញថា ខ្មែរក្រោមភាគច្រើនដែលបានស្ទង់មតិនៅខ្វះខាតការយល់ដឹងពីសិទ្ធិនានារបស់ខ្លួនតាមច្បាប់ជាតិ និងបែបបទក្នុងការទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិ

ខ្មែរ ដោយអ្នកឆ្លើយតបរហូតដល់ចំនួន ៩១,៦០% ពុំបានដឹងអំពីសិទ្ធិជាពលរដ្ឋរបស់ខ្មែរក្រោមក្រោមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ស្តីពីសញ្ជាតិនោះទេ។ ការស្រាវជ្រាវនេះបង្ហាញថា ចំនួន ៥៩,៥០% នៃអ្នកឆ្លើយតបមិនធ្លាប់ស្នើសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនោះទេ ដោយការពន្យល់ជាញឹកញាប់លើបញ្ហានេះ គឺដោយសារតែពួកគាត់មិនទទួលបានព័ត៌មានអំពីរបៀបដាក់ពាក្យស្នើសុំ (ចំនួន ២៥,៩៥% នៃអ្នកឆ្លើយតប) និងថា ពួកគាត់ពុំបានដឹងថាតើអ្នកណាអាចជួយពួកគាត់បាន (ចំនួន ១៦,០៣%)។ របកគំហើញនៃស្រាវជ្រាវបង្ហាញថា កង្វះភាពច្បាស់លាស់ និងភាពប្រាកដប្រជាផ្នែកច្បាប់ដែលបង្កើតឡើងតាមរយៈភាពមិនស៊ីសង្វាក់គ្នារវាងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលដែលថាពលរដ្ឋខ្មែរក្រោមគឺជាពលរដ្ឋខ្មែរ និងប្រការដែលពុំមានបែបបទផ្នែកច្បាប់ ឬផ្នែករដ្ឋបាលច្បាស់លាស់ដើម្បីឱ្យពួកគាត់អាចទទួលបានសិទ្ធិជាពលរដ្ឋនៅក្នុងការអនុវត្តជាក់ស្តែង កំពុងតែបង្កជាឧបសគ្គដល់ពលរដ្ឋខ្មែរក្រោមក្នុងការទទួលបានសិទ្ធិទាំងនេះនៅឡើយ។

របាយការណ៍ផ្តល់ជូននូវអនុសាសន៍មួយចំនួនដល់ភាគីពាក់ព័ន្ធ រួមមាន រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងភាពចាំបាច់ក្នុងការបញ្ជាក់ពីភាពច្បាស់លាស់ក្នុងក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងនីតិវិធីបែបបទ ដែលពលរដ្ឋខ្មែរក្រោមអាចដាក់ពាក្យស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបាន។ ក.ជ.ទ, ម.ស.ម.ក និង ស.ខ.ក.ក.ស.ម.អ សង្ឃឹមថា របាយការណ៍ និងអនុសាសន៍ទាំងនោះ នឹងជួយធ្វើឱ្យស្ថានភាពរបស់ពលរដ្ឋខ្មែរក្រោមនៅកម្ពុជាបានល្អប្រសើរ និងផ្តល់ជាភស្តុតាងបន្ថែមលើភាពចាំបាច់ឱ្យមានចំណាត់ការកាន់តែប្រសើរដើម្បីធានាថាពលរដ្ឋខ្មែរក្រោមអាចទទួលបានសិទ្ធិជាពលរដ្ឋរបស់ខ្លួននៅក្នុងការអនុវត្តជាក់ស្តែង។

**កញ្ញា ស្រី សុជាវី នាយិកាប្រតិបត្តិ ក.ជ.ទ មានប្រសាសន៍ថា ៖**

*"ដើម្បីធ្វើឱ្យស្ថានភាពល្អប្រសើរ កសាងទំនុកចិត្ត និងភាពជឿជាក់ ព្រមទាំងកាត់បន្ថយជម្លោះទៅបាន រដ្ឋាភិបាលគួរធានាថា ពលរដ្ឋខ្មែរក្រោមអាចទទួលបានអត្តសញ្ញាណប័ណ្ណ និងការអប់រំត្រឹមត្រូវ ហើយនិងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ និងសេវាសង្គមផ្សេងៗដែលពួកគាត់អាចទទួលបាន។ ស្ថាប័នពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋាភិបាល អង្គការ និងសង្គមស៊ីវិល ចាំបាច់ត្រូវតែបន្តការងាររបស់ខ្លួនដើម្បីធ្វើកំណែទម្រង់ច្បាប់ ដោយពិចារណាទៅលើតម្រូវការរបស់ពលរដ្ឋខ្មែរក្រោម តាមរយៈយន្តការប្រកបដោយតម្លាភាព និងត្រឹមត្រូវដើម្បីដោះស្រាយជម្លោះ និងធ្វើឱ្យប្រសើរនូវទំនាក់ទំនងរវាងអាជ្ញាធរមូលដ្ឋាន និងពលរដ្ឋខ្មែរក្រោម។ ការធ្វើដូច្នេះ បញ្ហាអាចត្រូវបានដោះស្រាយដោយជោគជ័យ និងសន្តិភាពនៅតាមមូលដ្ឋាន។"*

**លោក ឌុច ពិសិដ្ឋ នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក មានប្រសាសន៍ថា ៖**

*"ទោះបីជាមានការអះអាងពីអាជ្ញាធរកម្ពុជាថា ខ្មែរក្រោម ត្រូវបានចាត់ទុកថាជាពលរដ្ឋខ្មែរយ៉ាងណាក្តី របាយការណ៍នេះបង្ហាញថា ពលរដ្ឋខ្មែរក្រោមនៅតែប្រឈមនឹងការទទួលឋានៈជាផ្លូវការទៅតាមច្បាប់នៅក្នុងប្រទេសកម្ពុជា និងបន្តប្រឈមនឹងបញ្ហាធ្ងន់ធ្ងរមួយចំនួន ដូចជា ការរើសអើង និងកង្វះលំនៅដ្ឋាន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ការថ្លែងរបស់រដ្ឋាភិបាលចាំបាច់ត្រូវតែស៊ីសង្វាក់ជាមួយនឹងការអនុវត្តសកម្មភាពក្នុងការផ្តល់នូវគោលនយោបាយមួយដែលមានការធានាដោយច្បាប់ និងច្បាស់លាស់ ដើម្បីឱ្យពលរដ្ឋខ្មែរក្រោមអាចទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណ និងធានាថាពួកគាត់អាចទទួលបានសិទ្ធិផ្សេងៗទៀតក្នុងឋានៈជាពលរដ្ឋ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា។"*

*លោក សឹន ជុំជួន នាយកកម្មវិធីនៃ ស.ខ.ក.ក.ស.ម.អ មានប្រសាសន៍ថា ៖*

*"ខ្មែរក្រោម គឺជាក្រុមជនជាតិដើមភាគតិចដែលមានដើមកំណើតខ្មែរ។ ពេលបានមករស់នៅព្រះរាជាណាចក្រកម្ពុជា ពួកគាត់គួរតែត្រូវបានប្រព្រឹត្តឱ្យដូចជាពលរដ្ឋខ្មែរ អនុលោមតាមច្បាប់ជាតិ និងបទដ្ឋានពាក់ព័ន្ធ ព្រមទាំងគួរទទួលបានសិទ្ធិដូចៗគ្នាដោយពុំមានការរើសអើងអ្វីឡើយ។"*

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖

ក.ជ.ទ ៖ លោកស្រី ស៊ឹម ចន្ធា ប្រធានគម្រោង តាមរយៈទូរសព្ទ + ៨៥៥ (០) ៩៥ ៨០៧ ៣៧១ ឬ អ៊ីម៉ែល ៖ act@act.org.kh ឬ កញ្ញា ស្រី សុជាវី នាយិកាប្រតិបត្តិ តាមរយៈទូរសព្ទ + ៨៥៥ (០) ២៣ ២១៧ ៨៣០ ឬ អ៊ីម៉ែល director@act.org.kh។

ម.ស.ម.ក ៖ លោក ឌុច ពិសិដ្ឋ នាយកផ្នែកតស៊ូមតិ តាមរយៈទូរសព្ទ +៨៥៥ (០)១២ ៧១២ ៣៧១ ឬ អ៊ីម៉ែល duchpiseth@cchrcambodia.org ឬ កញ្ញា ខេតធី ចនស្តុន ទីប្រឹក្សាផ្នែកច្បាប់ តាមរយៈទូរសព្ទ + ៨៥៥ (០) ៧៧ ៨៤២ ៦២៧ ឬ អ៊ីម៉ែល katie.johnston@cchrcambodia.org។

ស.ខ.ក.ក.ស.ម.អ ៖ លោក សឹន ជុំជួន នាយកកម្មវិធី តាមរយៈទូរសព្ទ +៨៥៥ (០) ១១ ៧២៤ ៥៨៣ ឬ តាមរយៈអ៊ីម៉ែល chumchuon@kkkhrda.org ឬ oudomvireahpong@gmail.com៕